ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ២០០៩ ព.ណ ន.អវឯ

ថ្ងៃអង្គារ ៩រោច ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៦

សេចក្តីជូនដំណឹង

ស្តីពីថ្លៃលក់រាយប្រេងឥន្ធនៈនៅតាមស្ថានីយប្រចាំសប្តាហ៍ចាប់ពីថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៦

- យោងប្រកាសអន្តរក្រសួងលេខ០០៨៣ ពណ. អវឯ.ប្រក ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងក្រសួងរ៉ែ និងថាមពល ស្តីពីការកំណត់រូបមន្តសម្រាប់កែសម្រួលថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា
- យោងលើការព្រមព្រៀង លើរូបមន្តកំណត់តម្លៃជាមួយក្រុមហ៊ុនប្រេងឥន្ធនៈដែលប្រកបអាជីវកម្មនៅកម្ពុជា
- យោងការប្រែប្រួលនៃតម្លៃប្រេងឥន្ធនៈលើទីផ្សារក្នុងតំបន់និងអន្តរជាតិ

រាជរដ្ឋាភិបាលបាន **១.** បន្តបញ្ចុះចំនួន **៦,៥សេនដុល្លារ/លីត្រ** ក្នុងគោលបំណងជួយសម្រួលដល់ជីវភាពរបស់ប្រជាពលរដ្ឋ **២. បន្តបញ្ចុះ ១សេនដុល្លារ/លីត្របន្ថែមទៀត** ដោយសារថ្លៃប្រេងសាំងអន្តរជាតិឡើងលើសពី ៩០ដុល្លារ/បារ៉ែល និងប្រេងម៉ាស៊ូតអន្តរជាតិឡើងលើស ១០០ដុល្លារ/បារ៉ែល **៣. ពន្ធគយ ០ (សូន្យ) ដុល្លារ** និង **៤.** ផ្អែកតាមសកាពការណ៍ និងថ្លៃប្រេងឥន្ធនៈបន្តកើនឡើងនៅទីផ្សារអន្តរជាតិ ក៏ដូចជាថ្លៃដឹកជញ្ជូននិងថ្លៃធានារ៉ាប់រងមានការកើនឡើងខ្ពស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានសម្រេច **បញ្ចុះអាករបន្ថែមលើប្រេងសាំង និងប្រេងម៉ាស៊ូតមក ០ (សូន្យ) ដុល្លារ, បញ្ចុះអាករពិសេសលើប្រេងសាំងពី ៣០% មក ១៥% និងប្រេងម៉ាស៊ូត ពី ៤% មក ០% និង បញ្ចុះអាករលើតម្លៃបន្ថែមលើប្រេងសាំងពី ១០% មក ៤% និងប្រេងម៉ាស៊ូត ពី ១០% មក ០% ដោយរាជរដ្ឋាភិបាលទទួលបន្ទុកជំនួសសរុបចំនួន ៦% សម្រាប់ប្រេងសាំង និង ១០% សម្រាប់ប្រេងម៉ាស៊ូត**។

ដូច្នេះថ្លៃលក់រាយប្រេងឥន្ធនៈត្រូវអនុវត្ត**ជារៀងរាល់សប្តាហ៍ចាប់ពីវេលាម៉ោង ១ រសៀលថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៦ រហូតដល់ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៦** គឺត្រូវលក់ **៤ ៧០០រៀល/លីត្រ** សម្រាប់ប្រេងសាំងធម្មតា (Gasoline 92) និង **៥ ០៥០រៀល/លីត្រ** សម្រាប់ប្រេងម៉ាស៊ូត (Gasoil 10ppm)។

តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារកម្ពុជា

ល.រ	អធិប្បាយ	ប្រេងសាំងធម្មតា/លីត្រ Gasoline 92	ប្រេងម៉ាស៊ូត/លីត្រ Gasoil 10ppm
១	ថ្លៃប្រេងអន្តរជាតិជាមធ្យម (Average MOPS)	០,៧៣៥២ ដុល្លារ	០,៩២៨១ ដុល្លារ
២	ពន្ធ៖	០,០៧៨៥ ដុល្លារ	០,០០០០ ដុល្លារ
	ពន្ធគយ	០,០០០០ ដុល្លារ	០,០០០០ ដុល្លារ
	អាករបន្ថែម	០,០០០០ ដុល្លារ	០,០០០០ ដុល្លារ
	អាករពិសេស (ប្រេងសាំងបញ្ចុះពី ៣០% មក ១៥% និងប្រេងម៉ាស៊ូតបញ្ចុះពី ៤% មក ០%)	០,០៧៨៥ ដុល្លារ	០,០០០០ ដុល្លារ
៣	បុព្វលាភ (Premium)	០,២០ ដុល្លារ	០,២៣ ដុល្លារ
៤	អាករលើតម្លៃបន្ថែម (ប្រេងសាំងបញ្ចុះពី ១០% មក ៤% និងប្រេងម៉ាស៊ូតបញ្ចុះពី ១០% មក ០%)	០,០៤០៥ ដុល្លារ	០,០០០០ ដុល្លារ
៥	ថ្លៃលក់រាយ/លីត្រ (គិតជាដុល្លារ)	១,០៥៤២ ដុល្លារ	១,១៥៨១ ដុល្លារ
៦	ថ្លៃធានានិរន្តរភាពនៃការផ្គត់ផ្គង់ (ដោយគិតបញ្ចូលទាំងថ្លៃដឹកជញ្ជូន និងសេវាធានារ៉ាប់រងដែលក្រុមហ៊ុនត្រូវទទួលបន្ទុក)	០,១២១៥ ដុល្លារ	០,១១៥០ ដុល្លារ
៧	ក្រុមហ៊ុនប្រេងឥន្ធនៈបញ្ចុះតម្លៃ	០,០១ ដុល្លារ	០,០១ ដុល្លារ
៨	ថ្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជាដុល្លារ)	១,១៧ ដុល្លារ	១,២៦ ដុល្លារ
៩	ថ្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជារៀល)	៤ ៧០០ រៀល	៥ ០៥០ រៀល

សម្គាល់៖ - ថ្លៃប្រេងឥន្ធនៈមុនការបញ្ចុះអាករបន្ថែម, អាករពិសេស និងអាករលើតម្លៃបន្ថែម៖ **ប្រេងសាំង ៤ ៨៥០រៀល/លីត្រ និងប្រេងម៉ាស៊ូត ៥ ៣៥០រៀល/លីត្រ**។
- អត្រាប្តូរប្រាក់ផ្លូវការ ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៦ ដែលស្មើនឹង ៤ ០២៧រៀល/ដុល្លារអាមេរិក។
- ថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជាដែលបានគណនា និងបង្ហាញខាងលើ គឺផ្អែកលើតម្លៃប្រេងឥន្ធនៈដែលបានប្រែប្រួលនៅលើទីផ្សារអន្តរជាតិ ស្រដៀងតាមវិធីសាស្ត្រដូចបានយោងខាងដើម។ <u>បណ្តាស្ថានីយលក់រាយប្រេងឥន្ធនៈនៅកម្ពុជា អាចលក់ប្រេងក្នុងតម្លៃណាមួយ ដែលទាបជាងថ្លៃដែលបានគណនាខាងលើ តាមការប្រកួតប្រជែងដាក់ស្នែងនៃទីផ្សារនៅកម្ពុជា</u>។

អាស្រ័យហេតុនេះ សូមសាធារណជនមេត្តាជ្រាបថាថ្លៃលក់រាយប្រេងឥន្ធនៈនៅតាមស្ថានីយ នឹងត្រូវដាក់ចេញជារៀងរាល់**ថ្ងៃអង្គារ វេលាម៉ោង ១ រសៀល** និងសូមគ្រប់ស្ថានីយលក់រាយប្រេងឥន្ធនៈទាំងអស់ប្រតិបត្តិឱ្យបានគត់មត់តាមសេចក្តីជូនដំណឹងនេះ។

១៥-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទ្រុងមាន់ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទំនាក់ទំ[illegible]
អ៊ីម៉ែល៖ cabin[illegible]